ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា
មហាវិទ្យាល័យទស្សនវិជ្ជា សាសនា និងនីតិសាស្ត្រ

# របៀបតាក់តែងសាលក្រមរដ្ឋប្បវេណី

បទឧទ្ទេសនាមដោយ: លោក ម៉ុង មុនីសោភា
ចៅក្រមសាលាឧទ្ធរណ៍បាត់ដំបង



ឆ្នាំសិក្សា ២០២២

# មាតិកា

១-ក្បាលសាលក្រម

២-អង្គហេតុ និងចំណុចវិវាទ

៣-សំអាងហេតុ

៤-សេចក្ដីសម្រេចបញ្ចប់



# ១-ក្បាលសាលក្រម

# ១-ក្បាលសាលក្រម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ
(១៨៩ ក.១ ចំ.ក)
សញ្ញាណនៃរឿងក្តី
សំណុំរឿងរដ្ឋប្បវេណីលេខ ........
ចំណងជើង (១៨០, ១៨១, ១៨៣, ២៣៦ ក.៤)
សាលក្រមលេខ ...........

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

(១២៩ ថ្មី វ.នុ)

សាលាដំបូងរាជធានីភ្នំពេញ

បានទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី... ខែ... ឆ្នាំ ២០២២ ម៉ោង..... និង បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសសាលក្រមនាថ្ងៃទី ... ខែ ... ឆ្នាំ ២០២២ ម៉ោង..... (១៨៩ ក.១ ចំ.ខ)

# ១-ក្បាលសាលក្រម

**ចៅក្រមជំនុំជម្រះ**

លោក **ម៉ុង មុនីសោភា** ចៅក្រមជំនុំជម្រះ

**ក្រឡាបញ្ជីសវនាការ**

លោក ................ ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ



# ១-ក្បាលសាលក្រម

**-ដើមចោទ÷** ឈ្មោះ ................. ភេទ....... អាយុ.......ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ.... ផ្លូវ..... សង្កាត់........... ខណ្ឌ .......... រាជធានីភ្នំពេញ។

ដែលមានលោក ........... ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ។

មានការិយាល័យផ្ទះលេខ.... ផ្លូវ..... សង្កាត់...... ខណ្ឌ...... រាជធានីភ្នំពេញ។

**-ចុងចម្លើយ÷** ឈ្មោះ .................. ភេទ...... អាយុ......ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ.... ផ្លូវ..... សង្កាត់........... ខណ្ឌ .......... រាជធានីភ្នំពេញ។

ដែលមានលោក ............... ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ។

មានការិយាល័យផ្ទះលេខ.... ផ្លូវ..... សង្កាត់...... ខណ្ឌ....... រាជធានីភ្នំពេញ។

(១៨៩ ក.១ ចំ.គ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

# ២-អង្គហេតុ និងចំណុចវិវាទ

# ២-អង្គហេតុ និងចំណុចវិវាទ

**អង្គហេតុ និង ចំណុចវិវាទ** (១៨៩ ក.១ ចំ.ឃ)

**តើអង្គហេតុ និង ចំណុចវិវាទត្រូវសរសេរអ្វីខ្លះ?**

ត្រូវសរសេរខ្លឹមសារសំខាន់ៗដោយផ្អែកលើសេចក្ដីថ្លែងការណ៍របស់គូភាគី (១៨៩ ក.២) ហើយបើមិនច្បាស់លាស់ ឬផ្ទុយគ្នា ត្រូវប្រើសិទ្ធិឲ្យបំភ្លឺ (៩០)។

**ចំណុចត្រូវសរសេរ÷**

ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

ខ. ដំណើររឿងក្ដី និង ចំណុចវិវាទ

ខ.១. ការសង្ខេបអំពីរឿងក្ដី

ខ.២. អង្គហេតុដែលគ្មានវិវាទ

ខ.៣. ចំណុចវិវាទ

ខ.៤. ការអះអាងរបស់ភាគីស្ដីពីចំណុចវិវាទ



# ២-អង្គហេតុ និងចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្តី៖

ជាការបង្ហាញខ្លឹមសារត្រួសៗនៃរឿងក្តី វាជាការបង្ហាញឲ្យបានច្បាស់លាស់អំពីកម្មវត្ថុនៃបណ្តឹង។ មិនមែនជាការសរសេរឡើងវិញទាំងស្រុងអំពីការអះអាងរបស់ដើមចោទនោះទេ។

ឧទាហរណ៍៖ ក្នុងរឿងក្តីនេះដើមចោទបានចុះកិច្ចសន្យាលក់ទិញ.........ជាមួយនឹងចុងចម្លើយនៅថ្ងៃទី......... ហើយអះអាងថា ចុ.ចំមិនបានបង់ប្រាក់ថ្លៃលក់ទិញ ហើយទាមទារចុ.ចំឲ្យបង់ប្រាក់។

### ខ.២. អង្គហេតុដែលគ្មានវិវាទ៖

អង្គហេតុចម្បង និង អង្គហេតុប្រយោលសំខាន់ៗត្រូវសរសេរអង្គហេតុដែលភាគីគ្មានវិវាទ។

ឧទាហរណ៍៖ នៅក្នុងរឿងក្តីនេះ ភាគីបានឯកភាពគ្នាថាមានកិច្ចសន្យាលក់ទិញ.........។



# ២-អង្គហេតុ និងចំណុចវិវាទ

## ខ.៣. ចំណុចវិវាទ៖

ករណីតុលាការទទួលស្គាល់អត្ថិភាពនៃអង្គហេតុមួយ តុលាការត្រូវផ្អែកលើភស្តុតាង (១២៣) ហេតុនេះអង្គហេតុដែលភាគីម្ខាងទៀតបដិសេធ ឬមិនបានដឹង វានឹងក្លាយទៅជាចំណុចវិវាទ។

ករណីតុលាការវាយតម្លៃអំពី "កំហុស" តុលាការត្រូវផ្អែកលើអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុដែលភាគីបានអះអាង ពេលនោះអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនោះហើយនឹងក្លាយទៅជាចំណុចវិវាទ។

ឧទាហរណ៍៖

**ដ.ច**
-០១.០១.២២ ដ.ចបានលក់ផ្ទះឲ្យចុ.ចំក្នុងតម្លៃ ២០លានរ
-ដ.ចបានប្រគល់ផ្ទះឲ្យចុ.ចំ
-ចុ.ចំមិនបានប្រគល់ប្រាក់
ហេតុនេះ ដ.ចទាមទារឲ្យចុ.ចំបង់ប្រាក់

**ចុ.ចំ**
០១.០១.២២ ចុ.ចំបានទទួលផ្ទះមែន ប៉ុន្តែដ.ច ជាអ្នកឲ្យមិនមែនទិញលក់ទេ។

ដូច្នេះការមាន ឬមិនមានកិច្ចសន្យាលក់ទិញនឹងក្លាយជាចំណុចវិវាទ។



# ២-អង្គហេតុ និងចំណុចវិវាទ

**ដ.ច**
-០១.០១.២២ ដ.ចបានលក់ផ្ទះឲ្យចុ.ចំក្នុងតម្លៃ ២០លានរ
-ដ.ចបានប្រគល់ផ្ទះឲ្យចុ.ចំ
-ចុ.ចំមិនបានប្រគល់ប្រាក់
ហេតុនេះ ដ.ចទាមទារឲ្យចុ.ចំបង់ប្រាក់

**ចុ.ចំ**
០១.០១.២២ ចុ.ចំបានទទួលផ្ទះមែន ប៉ុន្តែចុ.ចំបានបង់ប្រាក់នៅពេលប្រគល់នោះរួចហើយ។

ដូច្នេះការមាន ឬមិនមានកិច្ចសន្យាលក់ទិញមិនក្លាយជាចំណុចវិវាទនោះទេ ប៉ុន្តែការមាន ឬមិនមានការសងទៅវិញទេដែលត្រូវក្លាយជាចំណុចវិវាទ។

***សរសេរចំណុចវិវាទដែលតុលាការបានកំណត់យ៉ាងជាក់លាក់រួចហើយ៖***

***ឧទាហរណ៍÷***

***តើដ.ចពិតជាបានបង្កើតកិច្ចសន្យាលក់ទិញជាមួយចុ.ចំដែរឬទេ? ឬ***

***តើចុ.ចំបានបង់ប្រាក់ថ្លៃលក់ទិញឲ្យដ.ចដែរឬទេ?***



# ២-អង្គហេតុ និងចំណុចវិវាទ

**២.៤. ការអះអាងរបស់ភាគីស្ដីពីចំណុចវិវាទ÷**

-សរសេរអំពីការអះអាងរបស់គូភាគីដែលទាក់ទងនឹងចំណុចវិវាទ ត្រង់ចំណុចវិវាទនីមួយៗ

-អាចសរសេរពីភាគីដែលមានបន្ទុកអះអាង និងបញ្ជាក់ភស្តុតាងអំពីវិវាទនោះ មុនតាមលំដាប់លំដោយ



# ៣-សំអាងហេតុ

# ៣-សំអាងហេតុ

## សំអាងហេតុ

(១៨៩ ក.១ ចំ.ង)

I- ការវិនិច្ឆ័យចំណុចវិវាទ ត្រូវបង្ហាញអំពីទំនាក់ទំនងអង្គហេតុដែលទទួលស្គាល់ និង ភស្តុតាងជាក់លាក់ដែលទាក់ទងនឹងអង្គហេតុនេះ ហើយត្រូវសរសេរឲ្យបានក្បោះក្បាយ។

ក.មាន ០២ ករណីៈ

ក.១ តើតុលាការបានទទួលស្គាល់អង្គហេតុមួយណា ពីភស្តុតាងមួយណា?

ក.២ តើតុលាការបានវិនិច្ឆ័យយ៉ាងដូចម្តេចផ្អែកតាមអង្គហេតុដែលបានទទួលស្គាល់?

ខ.ក្នុងករណីដែលត្រូវបកស្រាយច្បាប់ តុលាការត្រូវបង្ហាញអំពីការយល់ឃើញដែលនាំឲ្យមានការបកស្រាយច្បាប់ និងមូលហេតុនោះ។ មាត្រាច្បាប់ដែលតុលាការយកមកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យ និងការពន្យល់បន្ថែមទៅលើការវិនិច្ឆ័យ គឺជាផ្នែកមួយនៃការវិនិច្ឆ័យរបស់តុលាការ ហេតុនេះ ហើយត្រូវលើកមកសរសេរនៅក្នុងសាលក្រម។



# ៣-សំអាងហេតុ

*II-* កម្មវត្ថុនៃការទទួលស្គាល់ដោយផ្អែកលើភស្តុតាងគឺអង្គហេតុ។ មិនត្រូវសរសេរជាលក្ខណៈនៃការទទួលស្គាល់នូវសិទ្ធិ និងកាតព្វកិច្ចភ្លាមៗដោយផ្អែកតាមភស្តុតាងនោះបានទេ។

ឧទាហរណ៍ ១៖

មិនគប្បីទេ៖ ផ្អែកតាមចម្លើយសាក្សីឈ្មោះ ................. តុលាការទទួលស្គាល់ថា ចុងចម្លើយមានកាតព្វកិច្ចបង់ប្រាក់ចំនួន.............. ឲ្យដើមចោទ



# ៣-សំអាងហេតុ

គប្បី៖ ផ្អែកតាមចម្លើយសាក្សីឈ្មោះ ... តុលាការទទួលស្គាល់ថា ដើមចោទបានប្រគល់ប្រាក់ចំនួន... ឲ្យចុងចម្លើយស្របតាមកិច្ចសន្យា......។ ដូច្នេះ តុលាការទទួលស្គាល់ថា ចុងចម្លើយមានកាតព្វកិច្ចបង់ប្រាក់ចំនួន......... ឲ្យដើមចោទ។

ឧទាហរណ៍ ២៖

មិនគប្បីទេ៖ ពុំមានភស្តុតាងដែលអាចបញ្ជាក់អំពីការរំលោយកិច្ចសន្យានោះទេ។

គប្បី៖ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់ថា ដើមចោទបានបង្ហាញឆន្ទៈអំពីការរំលោយកិច្ចសន្យានេះទៅកាន់ចុងចម្លើយទេ។ ហេតុនេះតុលាការមិនអាចទទួលស្គាល់អំពីការរំលោយកិច្ចសន្យានេះទេ។



# ៣-សំអាងហេតុ

*III-* ចំពោះការទទួលស្គាល់អង្គហេតុ គឺគ្រាន់តែសរសេរអំពីអង្គហេតុដែលភាគីណាមួយមានបន្ទុកត្រូវបញ្ជាក់ភស្តុតាងហើយបង្ហាញថា តុលាការទទួលស្គាល់អង្គហេតុនោះតាមរយៈភស្តុតាង ឬក៏ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់ទេ ម្យ៉ាងទៀតពុំចាំបាច់សរសេរថា គ្មានអង្គហេតុ ឬអាចទទួលស្គាល់អំពីអត្ថិភាពនៃអង្គហេតុផ្ទុយនោះទេ។

ឧទាហរណ៍៖

មិនគប្បីទេ៖ តុលាការទទួលស្គាល់ថា ចុងចម្លើយមិនទាន់បានបង់ប្រាក់ថ្លៃលក់ទិញឲ្យដើមចោទទេ។

គប្បី៖ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់អង្គហេតុដែលលើកឡើងថា ចុងចម្លើយបានបង់ប្រាក់ថ្លៃលក់ទិញឲ្យទៅដើមចោទទេ។



# ៣-សំអាងហេតុ

*IV- ករណីដែលតុលាការអាចទទួលស្គាល់អង្គហេតុ (មានភស្តុតាងផ្ទាល់)៖* ករណីដែលមានវិវាទអំពីការបង្កើត ឬមិនបានបង្កើតនូវលិខិតកិច្ចសន្យាលក់ទិញនៅក្នុងរឿងក្តីដែលមានលិខិតកិច្ចសន្យា។

ឧទាហរណ៍៖

ផ្អែកតាមភស្តុតាង .....(កិច្ចសន្យា)....... តុលាការទទួលស្គាល់ថា កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះត្រូវបានបង្កើតឡើង។



# ៣-សំអាងហេតុ

*V- ករណីដែលតុលាការអាចទទួលស្គាល់អង្គហេតុ* *(គ្មានភស្តុតាងផ្ទាល់)*៖ *ត្រូវបញ្ជាក់ឲ្យបានច្បាស់ថាតើបានទទួលស្គាល់អង្គហេតុផ្ទាល់បែបណាដោយផ្អែកលើភស្តុតាងបែបណា?*

*ឧទាហរណ៍៖*

*ផ្អែកតាមភស្តុតាង .....(មិនមែនជាកិច្ចសន្យា)......តុលាការទទួលស្គាល់ថា ចុងចម្លើយបានជួបបញ្ហានឹងប្រាក់ដើមទុកសម្រាប់ការធ្វើអាជីវកម្មនៅអំឡុង.............. ហើយបានស្នើសុំកម្ចីឥណទានពី ក ហើយ ក បានបដិសេធនឹងសំណើនោះ ហើយបានផ្តល់យោបល់ឲ្យចុងចម្លើយលក់ដីនៃរឿនក្តីនេះដែលជាកម្មសិទ្ធិរបស់ចុងចម្លើយ ហើយនៅពេលនោះ ក បានណែនាំដើមចោទដែលកំពុងស្វែងរកដីទៅកាន់ចុងចម្លើយ .............។ ដូច្នេះ កិច្ចសន្យាទិញលក់ដីត្រូវបានបង្កើតឡើងរវាងដើមចោទ និងចុងចម្លើយ។*



# ៣-សំអាងហេតុ

VI- ករណីដែលតុលាការអាចទទួលស្គាល់អង្គហេតុ៖ ករណីដែលភាគីម្ខាងទៀតលើកឡើងនូវអង្គហេតុតវ៉ា (ឧទាហរណ៍ ចុងចម្លើយថាផ្ទះដែលខ្លួនបាននេះមិនមែនជាការទិញលក់ទេតែជាអំណោយ) ដូច្នេះត្រូវបកស្រាយអំពីការអះអាងរបស់ភាគីម្ខាងទៀត។

ឧទាហរណ៍៖

ចុងចម្លើយអះអាងថា ផ្ទះនេះមិនមែនជាផ្ទះដែលខ្លួនបានដោយការទិញទេ តែជាអំណោយ ប៉ុន្តែតុលាការមិនអាចទទួលយកការអះអាងនេះទេ ដោយហេតុថា .................។



# ៣-សំអាងហេតុ

## VII- ករណីដែលតុលាការមិនអាចទទួលស្គាល់អង្គហេតុ៖

ឧទាហរណ៍៖

ផ្អែកតាមភស្តុតាង.............................. តុលាការទទួលស្គាល់អង្គហេតុ....................។ ប៉ុន្តែទោះបីជាសរុបជារួមនូវអង្គហេតុដែលគ្មានវិវាទ និង អង្គហេតុដែលបានទទួលស្គាល់ខាងលើនេះក៏ដោយ ក៏តុលាការមិនអាចសន្និដ្ឋានបានថា អង្គហេតុ........................ ហើយក្រៅពីនេះ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់នូវអង្គហេតុ........................។



# ៣-សំអាងហេតុ

ករណីដែលតុលាការទទួលស្គាល់នូវអង្គហេតុប្រយោលផ្សេងទៀតដោយមិនប្រើការសន្និដ្ឋាននូវអង្គហេតុចម្បងផ្អែកតាមអង្គហេតុប្រយោលណាមួយ។

ឧទាហរណ៍៖

ផ្អែកតាមភស្តុតាង...............A.................តុលាការទទួលស្គាល់អង្គហេតុ..........a............។ ក្រៅពីនេះ ផ្អែកតាមភស្តុតាង ........B............ តុលាការទទួលស្គាល់អង្គហេតុ................b.................. តុលាការមិនអាចសន្និដ្ឋានអំពីអង្គហេតុ .......................c.................ដែលដើមចោទអះអាងផ្អែកតាមអង្គហេតុ ............a.........ទេ ហើយក្រៅពីនេះ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់នូវអង្គហេតុ ............c..............ទេ។



# ៣-សំអាងហេតុ

## VIII- អំពីការជឿលើសាក្សី៖

ភាគច្រើនសាក្សីខាងភាគីដើមចោទ និងចុងចម្លើយគាត់អះអាងផ្ទុយគ្នា ដូច្នេះតុលាការមិនអាចជឿគ្រប់សាក្សីនោះទេ។ ក្នុងករណីដែលតុលាការមិនជឿលើសាក្សីណាមួយ តុលាការត្រូវសរសេរអំពីមូលហេតុនោះ។

ឧទាហរណ៍៖

ការអះអាងរបស់សាក្សី............. មានចំណុចមិនច្បាស់លាស់ និងផ្ទុយគ្នាច្រើន ហេតុនេះតុលាការមិនអាចជឿជាក់បានទេ។

ការអះអាងរបស់សាក្សី.................. ផ្ទុយនឹងភស្តុតាង.................. ដូច្នេះតុលាការមិនអាចជឿជាក់បាននោះទេ។

**អំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី (៦៥)÷**

**អំពីការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន (១៩៦)÷**

**ត្រូវបញ្ជាក់ឲ្យច្បាស់ថាអាចអនុវត្តបណ្តោះអាសន្នបានចំណុចណានៃសេចក្តីសម្រេចបញ្ចប់ខ**



# ៩-សេចក្តីសម្រេចបញ្ចប់

# ៨-សេចក្តីសម្រេចបញ្ចប់

## សេចក្តីសម្រេចបញ្ចប់

### I- ករណីលើក និងប្រានចោល

១.លើកចោលពាក្យបណ្តឹង.................... (ករណីខ្វះល.ខបណ្តឹង)

២.ប្រានចោលការទាមទារ..................... (ករណីការទាមទារ អត់មូលហេតុ)

៣.ប្រានចោលការទាមទារផ្សេងពីនេះរបស់................. (ករណីតុលាការ ទទួលស្គាល់ការទាមទារមួយផ្នែក)



# ៨-សេចក្ដីសម្រេចបញ្ចប់

## II- ករណីទទួលស្គាល់នូវការទាមទារ

ជាការឆ្លើយតបទៅនឹងខ្លឹមសារនៃសាលក្រមដែលទាមទារនៅក្នុងពាក្យបណ្ដឹង

១.សាលក្រមផ្ដល់តាវកាលិក

បង្គាប់ឲ្យ........................បង់ប្រាក់ចំនួន..............

បង្គាប់ឲ្យ........................ប្រគល់ដី.................

២.សាលក្រមបង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជី

បង្គាប់ឲ្យ.............. ធ្វើនីតិវិធីចុះបញ្ជី.............(៥២៩ ក១) និង ប្រ.១០ក២ នៃប្រ.អន្តរក្រសួង

ចំណាំ៖ មិនត្រូវបង្គាប់ទៅមន្ត្រីចុះបញ្ជីឲ្យធ្វើ.......................ទេ ព្រោះមន្ត្រីទាំងនោះមិនមែនជាភាគី។



# ៨-សេចក្តីសម្រេចបញ្ចប់

## ៣ . សាលក្រមបញ្ជាក់

ជាសាលក្រមបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង ដូច្នេះត្រូវសរសេរថា "បញ្ជាក់ថា ......................"។ គប្បីជៀសវាងការប្រើប្រាស់ពាក្យពេចន៍ដែលធ្វើឲ្យច្រឡំជាមួយនឹងសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិក។

ឧទាហរណ៍៖ បញ្ជាក់ថា ដើមចោទមានកម្មសិទ្ធិលើដីដែល.....................

បញ្ជាក់ថា ដើមចោទមិនមានកាតព្វកិច្ចសងប្រាក់.................



# ៨-សេចក្ដីសម្រេចបញ្ចប់

## ៩.សាលក្រមបង្កើត ផ្លាស់ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត

ជាសាលក្រមដែលមានគោលបំណងបង្កើត ផ្លាស់ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ផ្អែកតាមរយៈសាលក្រមនោះ ដូច្នេះហើយត្រូវបង្ហាញឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងសិទ្ធិដែលត្រូវបានបង្កើតឡើងតាមរយៈសេចក្ដីសម្រេចបញ្ចប់។

គប្បីជៀសវាងការប្រើប្រាស់ពាក្យពេចន៍ ដែលធ្វើឲ្យច្រឡំជាមួយនឹងសាលក្រមដែលបង្គាប់ឲ្យផ្ដល់តាវកាលិក ឬសាលក្រមបញ្ជាក់។

ឧទាហរណ៍៖ ករណីលែងលះ៖ លែងលះដើមចោទ និងចុងចម្លើយ។

ករណីបណ្ដឹងតវ៉ាចំពោះការទាមទារ៖ មិនអនុញ្ញាតឲ្យអនុវត្តដោយបង្ខំលើចុងចម្លើយចំពោះដើមចោទ ផ្អែកតាមសាលក្រមនៃរឿងក្ដីនេះ ............................។



# ៨-សេចក្តីសម្រេចបញ្ចប់

*III- អំពីប្រាក់ប្រដាប់ក្តី (៦៥)៖ (សរសេរមុនប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន)*

*IV- អំពីការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន (១៩៦)៖*

ចៅក្រមជំនុំជម្រះ (១៨៥ ក ១)

ហត្ថលេខា (១៨៩ ក ៣)

ហត្ថលេខាជំនួស (១៨៩ ក ៤)



# សូមអរគុណសម្រាប់ការយកចិត្ត

# ទុកដាក់ស្តាប់...!